# សេចក្តីប្រកាសព័ត៌មាន

## គម្រោងបាឡុងហោះ ដើម្បីរៃអង្គាសទឹកប្រាក់ចំនួន ១លានដុល្លារអាមេរិក សម្រាប់អង្គការយូនីសេហ្វ   បានធ្វើដំណើរមកដល់ប្រទេសកម្ពុជា

**ភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤៖** បាឡុងហោះដែលកំពុងធ្វើដំណើរទៅកាន់ប្រទេសជាង ១០០ បានមកដល់ប្រទេសកម្ពុជា ហើយនៅព្រឹកថ្ងៃនេះនៅឯសួនច្បារមុខវត្តបុទុម វាត្រូវបានបង្ហោះឡើងដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារក្នុងការទទួលការអប់រំ និងដើម្បីរៃអង្គាសទឹកប្រាក់សម្រាប់ការងាររបស់អង្គការយូនីសេហ្វនៅទូទាំងពិភពលោក។

លោក អេនឌ្រូ ផាកឃឺ ដែលជាអ្នកបង្ហោះបាឡុងហោះនិងជាអ្នករៃអង្គាសថវិកាសម្រាប់អង្គការយូនីសេហ្វ បានមកដល់ខេត្តសៀមរាបកាលពីសប្តាហ៍មុន    ហើយបានបង្ហោះបាឡុងឲ្យកុមាររាប់រយនាក់បានទស្សនានៅឯបឋមសិក្សាជន្លង និងក្រោយមកបានបង្ហោះម្តងទៀតនៅឯបឋមសិក្សាដង្កោ នាទីក្រុងភ្នំពេញកាលពីថ្ងៃទី២៤ ខែមិថុនា។ បន្ទាប់ពីបង្ហោះបាឡុងជាលើកចុងក្រោយនាព្រឹកនេះ លោកនឹងបន្តដំណើរទៅកាន់ប្រទេសឡាវ។

លោក អេនឌ្រូ បានចាប់ផ្តើម **គម្រោងបាឡុងហោះពិភពលោកសម្រាប់កុមារ** នេះជាមួយអង្គការយូនីសេហ្វ នៅទីក្រុង អកឡេន ប្រទេសណូវែសហ្សេឡង់ កាលពីខែធ្នូ ឆ្នាំ២០១៣។ នៅក្នុងដំណើរបង្ហោះបាឡុងជុំវិញពិភពលោកនេះ រូបគាត់និងសហការីចំនួន២រូបផ្សេងទៀត មានគម្រោងនឹងទស្សនកិច្ចសាលាចំនួន២០០កន្លែង និងជួបកុមារប្រមាណជាង ៨ម៉ឺននាក់។

នៅក្នុងរយៈពេល៤ឆ្នាំខាងមុខ បាឡុងនេះនឹងត្រូវបានបង្ហោះទៅកាន់កន្លែងជាច្រើន ដូចជាឆ្លងកាត់បណ្តាភ្នំនានានៃតំបន់អាស៊ីកណ្តាល នៅតាមព្រៃនានានៃទ្វីបអាហ្វ្រិកនិងអាមេរិកឡាទីន ហើយជាចុងក្រោយនឹងត្រូវចុះចតនៅក្នុងប្រទេសឈីលី ក្នុងឆ្នាំ២០១៧។

លោក អេនឌ្រូ ផាកឃឺ បានមានប្រសាសន៍ថា "ខ្ញុំមានគំនិតក្នុងការហោះហើរសម្រាប់បុព្វហេតុអ្វីមួយ តាំងពីខ្ញុំនៅវ័យជំទង់ម្ល៉េះ ហើយខ្ញុំចេះតែចិញ្ចឹមចិត្តបែបនោះរហូតមក។ រហូតដល់ឆ្នាំ២០១០ ខ្ញុំបានសរសេរសំណើមួយទៅកាន់អង្គការយូនីសេហ្វ ហើយចាប់តាំងពីពេលនោះមកខ្ញុំគិតថាសុបិនរបស់ខ្ញុំចាប់ផ្តើមក្លាយជាការពិតបណ្តើរៗហើយ"។

លោកបានបន្តទៀតថា ខ្ញុំបានហោះហើរបាឡុងនៅតាមប្រទេសជាច្រើន ប៉ុន្តែខ្ញុំពុំដែលមានឱកាសហោះហើរនៅក្នុងទ្រង់ទ្រាយធំបែបនេះទេ។ កុមារភាគច្រើនដែលយើងនឹងជួប ពួកគេពុំដែលបានឃើញបាឡុងហោះបែបនេះពីមុនឡើយ។ ខ្ញុំក៏មានចិត្តសប្បាយរីករាយផងដែរ ដែលបានគាំទ្រដល់អង្គការយូនីសេហ្វ ដែលជាអង្គការពិភពលោក ជួយគាំទ្រដល់កុមារឲ្យទទួលបានការអប់រំ។

គម្រោងបង្ហោះបាឡុងនេះ មានគោលបំណងរៃអង្គាសថវិកាសម្រាប់អង្គការយូនីសេហ្វ តាមរយៈការបរិច្ចាគជាសាធារណៈ និងភាពជាដៃគូពាណិជ្ជកម្ម។

#####

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**


លោក អេនឌ្រូ ផាកឃឺ ប្រធានគគម្រោងប៉ាឡុងហោះពិភពលោកសម្រាប់កុមារ

ទូរស័ព្ទ (+៨៥៥) ៩៦ ៣២១ ២០៦៨ និង អ៊ីម៉ែល Andrew@flyinghighforkids.com

Facebook: www.facebook.com/flyinghighforkidsproject

គេហទំព័រ: www.flyinghighforkids.com

លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង អង្គការយូនីសេហ្វ កម្ពុជា

ទូរស័ព្ទ (+៨៥៥) ១២ ៧៣៣ ៩០៩ និង អ៊ីម៉ែល bmeas@unicef.org


**អំពីយូនីសេហ្វ**

យូនីសេហ្វលើកកម្ពស់សិទ្ធិនិងសុខុមាលភាពរបស់កុមារគ្រប់រូប នៅក្នុងគ្រប់ការងារទាំងអស់របស់យើង។ រួមគ្នាជាមួយនឹងដៃគូរបស់យើង យើងធ្វើការងារនៅក្នុងប្រទេសនិងដែនដីចំនួន១៩០ ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តខាងលើឲ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែង តាមរយៈការផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់កុមារដែលងាយរងគ្រោះជាងគេ និងមិនត្រូវបានគេយកចិត្តទុកដាក់ ដើម្បីជាប្រយោជន៍ ដល់កុមារគ្រប់រូបនៅគ្រប់ទិសទីទាំងអស់។ សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វនិងការងាររបស់អង្គការនេះនៅក្នុងប្រទេសកម្ពុជា សូមមើលគេហទំព័រ www.unicef.org.kh។